**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៤៨/២០២៥ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

# លទ្ធផលនៃជំនួបទ្វេភាគីរវាង សម្ដេចធិបតីនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ

នៅព្រឹកថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាទ្វេភាគីជាមួយ**ឯកឧត្តម** Lee Jae Myung ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ (សា.កូរ៉េ)។ **សម្ដេចធិបតី** បានសម្ដែងជាថ្មីម្ដងទៀតនូវការអបអរសាទរចំពោះ**ឯកឧត្តម** Lee Jae Myung ដែលបានជាប់ឆ្នោតជាប្រធានាធិបតី សា.កូរ៉េ ហើយបានលើកសរសើរអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អលើវិស័យជាច្រើន ដែលត្រូវបានលើកកម្ពស់ទៅជាភាពជាដៃគូយុទ្ធសាស្ត្រ កាលពីខែឧសភា ឆ្នាំ២០២៤ ដែលជាលទ្ធផលនៃការរីកចម្រើននៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងរយៈពេលជិត ៣ទសវត្សរ៍។ **សម្ដេចធិបតី** បានបញ្ជាក់ថា សា.កូរ៉េជាដៃគូវិនិយោគ និងប្រភពភ្ញៀវទេសចរសំខាន់មួយរបស់កម្ពុជា ហើយជាប្រទេសដែលទទួលពលករកម្ពុជាជាច្រើន ដែលនេះឆ្លុះបញ្ចាំងពីទំនាក់ទំនងដ៏ជិតស្និទ្ធមិនត្រឹមតែរវាងរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏រវាងប្រជាជននៃប្រទេសទាំងពីរផងដែរ។ **សម្ដេចធិបតី** ក៏បានជម្រាបជូន**ប្រធានាធិបតី** Lee ផងដែរថា **សម្ដេច**តែងតែយកចិត្តទុកដាក់ចំពោះសំណូមពរ និងកង្វល់ដែលបានលើកឡើងដោយអ្នកវិនិយោគបរទេស រួមទាំងអ្នកវិនិយោគកូរ៉េ តាមរយៈការជួបដោយផ្ទាល់ និងតាមវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។

**ប្រធានាធិបតី** Lee បានកោតសរសើរចំពោះទំនាក់ទំនងពិសេសរវាងប្រទេសយើងទាំងពីរ ហើយបានវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ប្រជាជនកូរ៉េកំពុងរស់នៅ និងធ្វើការនៅកម្ពុជា។ **ប្រធានាធិបតី** Lee បានបង្ហាញសុទិដ្ឋិនិយមថា ទំនាក់ទំនងរវាងប្រទេសទាំងពីរមានសក្ដានុពលធំធេងក្នុងការបន្តលើកកម្ពស់ទៅកម្រិតខ្ពស់ថែមទៀត។

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**សម្តេចធិបតី** និង**ប្រធានាធិបតី Lee** បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យសំខាន់ៗ រួមទាំងវិស័យការពារជាតិ និងសន្តិសុខ ដែលថ្នាក់ដឹកនាំទាំងពីរបានទទួលស្គាល់សមិទ្ធផលរួមគ្នាជាច្រើនក្នុងវិស័យនេះ។ ថ្នាក់ដឹកនាំទាំងពីរមានទស្សនៈដូចគ្នាថា ឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មសាយប័រ មិនមែនជាបញ្ហាដែលប្រទេសណាមួយប្រឈមមុខ និងអាចដោះស្រាយតែម្នាក់ឯងនោះទេ ដូច្នេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការក្នុងតំបន់ ជាពិសេសកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងកម្ពុជា និងសា.កូរ៉េ។ ក្នុងន័យនេះ **សម្តេចធិបតី** និង**ប្រធានាធិបតី Lee** បានឯកភាពគ្នាបង្កើត និងដាក់ឱ្យដំណើរការក្រុមការងារចម្រុះមួយនៅខែវិច្ឆិកា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធនឹងសាយប័រ ជាពិសេសពាក់ព័ន្ធនឹងជនជាតិកូរ៉េ។ **សម្តេចធិបតី** បានលើកឡើងថា ការសម្រេចចិត្តនេះ បង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំង និងបង្ក្រាប ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់ ដែលគំរាមកំហែងដល់សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពបុគ្គល។

ផ្អែកលើការពិភាក្សាជាវិជ្ជមាននៅថ្ងៃនេះ **ប្រធានាធិបតី Lee** បានសម្តែងនូវការគាំទ្រយ៉ាងខ្លាំងក្លាចំពោះកិច្ចសហប្រតិបត្តិការនេះ ហើយបានសន្យាថា នឹងពិចារណាលើបញ្ហាការងារ និងកាត់បន្ថយកម្រិតប្រកាសអាសន្នសម្រាប់ការធ្វើដំណើរ។ **ប្រធានាធិបតីសា.កូរ៉េ** បានធានាចំពោះ**សម្តេចធិបតី**ថា បញ្ហាឧក្រិដ្ឋកម្មសាយប័រនេះនឹងមិនជះឥទ្ធិពលអវិជ្ជមានដល់ទំនាក់ទំនងទ្វេភាគីជារួមរវាងកម្ពុជា និងសា.កូរ៉េទេ ហើយ**ប្រធានាធិបតី Lee** ទន្ទឹងរង់ចាំបំពេញទស្សនកិច្ចនៅកម្ពុជា នាពេលខាងមុខ។

**ថ្នាក់ដឹកនាំទាំងពីរ**បានឯកភាពគ្នាលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ ឱ្យធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីបង្កើនទំហំពាណិជ្ជកម្មទ្វេភាគី ទាក់ទាញការវិនិយោគកូរ៉េមកកម្ពុជា និងជំរុញទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ព្រមទាំងធ្វើការរួមគ្នាផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ រួមទាំងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់៕

ថ្ងៃចន្ទ ៦កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០២៥